# សេចក្តីសំរេច

*រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ១៩៩៤*

## សេចក្តីសំរេចលេខ ៧៣ សសរ

## ស្តីពីប្រាក់អាហារបន្ថែមសំរាប់កងយោធពលខេមរភូមិន្ទដែលមានរបួស ជំងឺ សំរាកព្យាបាលនៅតាមមន្ទីរពេទ្យ និងគិលានដ្ឋាន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះ បាទសម្តេចព្រះ នរោត្តមសីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិការ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**ប្រការ ១ :** ដោយប្រាក់អាហារបន្ថែមសំរាប់កងយោធពលខេមរភូមិន្ទ ដែលមានរបួស ជំងឺសំរាកព្យាបាលនៅតាមមន្ទីរពេទ្យចំនួន ២.០០០ រ ( ពីរពាន់រៀលគត់ ) ក្នុងមួយថ្ងៃ សំរាប់មួយនាក់ និង សំរាកព្យាបាលនៅតាមគិលានដ្ឋានចំនួន ១.៦០០ រ (មួយពាន់ប្រាំមួយរយរៀលគត់ ) ក្នុងមួយថ្ងៃសំរាប់មួយនាក់ ។

**ប្រការ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថ - លេខា និង ចុះហត្ថលេខាតទៅ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឬទ្ធិ | ហ៊ុន សែន |